ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ ៥៣៦២ PC.អក

ថ្ងៃ[illegible] ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០២០

## សេចក្ដីជូនដំណឹង(លើកទី៣)
## ស្ដីពី
ករណីដឹកយកត្រឡប់ទៅវិញនូវ Transformer ចំនួន 45 គ្រឿង ពីឃ្លាំងអគ្គិសនីកម្ពុជា
របស់ក្រុមហ៊ុន Taikang Eastern

**យោង** ៖ -លិខិតលេខ 4550 PC.អក ចុះថ្ងៃទី 28 ខែ កញ្ញា ឆ្នាំ 2020 របស់គណៈកម្មាធិការលទ្ធកម្មអគ្គិសនីកម្ពុជា ។
-លិខិតលេខ 3055 PC.អក ចុះថ្ងៃទី 15 ខែ កក្កដា ឆ្នាំ 2020 របស់គណៈកម្មាធិការលទ្ធកម្មអគ្គិសនីកម្ពុជា ។
-លិខិតរបស់អគ្គិសនីកម្ពុជា ចុះថ្ងៃទី 19 ខែ កក្កដា ឆ្នាំ 2017 ស្ដីពីការរឹបអូសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានិងបញ្ចប់កិច្ចសន្យាលើការផ្គត់ផ្គង់ Transformer ចំនួន 45 គ្រឿង ជូន អគ្គិសនីបាត់ដំបង ។
-កិច្ចសន្យាលេខ 1938 PC.អក ចុះថ្ងៃទី 30 ខែ វិច្ឆិកា ឆ្នាំ 2016 ។

អគ្គិសនីកម្ពុជា សូមជូនដំណឹងដល់លោកនាយកក្រុមហ៊ុន Taikang Eastern ឲ្យបានជ្រាបថា ៖ កន្លងមកអគ្គិសនីកម្ពុជា បានទំនាក់ទំនងនិងចេញលិខិតជូនដំណឹងដល់ក្រុមហ៊ុនចំនួន០២លើករួចមកហើយ ក្នុងនោះក៏មានការចុះផ្សាយតាមរយៈកាសែតរស្មីកម្ពុជាផងដែរ ក្នុងការស្នើសុំឲ្យដឹកយកត្រឡប់ទៅវិញនូវ Transformer ចំនួន 45 គ្រឿង ពីឃ្លាំងអគ្គិសនីកម្ពុជា(ជាសម្ភារដែលមិនបំពេញតាមលក្ខណៈបច្ចេកទេសរបស់អគ្គិសនីកម្ពុជា) ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននេះ មិនទាន់ឃើញមានចំណាត់ការពីក្រុមហ៊ុននៅឡើយ ។ ជាថ្មីម្ដងទៀត អគ្គិសនីកម្ពុជាសូមជូនដំណឹងជាលើកចុងក្រោយដោយទុករយៈពេលយ៉ាងយូរ ១៥ ថ្ងៃ ក្នុងការដឹកយកត្រឡប់ទៅវិញនូវ Transformer ចំនួន 45 គ្រឿង ពីឃ្លាំងអគ្គិសនីកម្ពុជា បន្ទាប់ពីក្រុមហ៊ុនទទួលបានលិខិតនេះ ។ ក្នុងករណីដែលក្រុមហ៊ុននៅតែមិនមានចំណាត់ការក្នុងការដឹកយកត្រឡប់ទៅវិញនូវ សម្ភារទាំងនេះចេញពីឃ្លាំងរបស់អគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជានឹងរឹបអូសយកសម្ភារទាំងនេះដែលកំពុងរក្សាទុកក្នុងឃ្លាំងអគ្គិសនីកម្ពុជាអស់រយៈពេលជាង ០៣ ឆ្នាំមកហើយ មកប្រកាសលក់ឡាយឡុងជាប្រភេទសម្ភារកកស្ទះខូចគុណភាពដោយពុំចាំបាច់មានការជូនដំណឹងដល់ក្រុមហ៊ុនម្ដងទៀតឡើយ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ស្នើលោកនាយកប្រញាប់រួសរាន់រៀបចំដឹកយកត្រឡប់ទៅវិញនូវ Transformer ចំនួន 45 គ្រឿង ពីឃ្លាំងអគ្គិសនីកម្ពុជា តាមសេចក្ដីជូនដំណឹងនេះ តាមការគួរ ។

សូម លោកនាយកទទួលនូវការរាប់អានអំពីខ្ញុំ ។

ជ. ប្រធានគណៈកម្មាធិការលទ្ធកម្ម

ហង់_នូច

**ចម្លងជូន:**
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-អង្គភាពប្រឆាំងអំពើពុករលួយ
ដើម្បីជូន "ជ្រាប"
-ឯកសារ-កាលប្បវត្តិ